**BMI0061**

# សម្ភាសន៍ជាមួយឈ្មោះ ផែត ចាន់ថូ ភេទប្រុស អាយុ៥៥ឆ្នាំ

**មុខងាររជំនាន់ខ្មែរក្រហម«ពេទ្យយោធា»**

**មុខងារបច្ចុប្បន្ន«គ្រូបង្រៀន»**

**ស្រុកកំណើតនៅភូមិរវៀង ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ**

**រស់នៅភូមិវាលហាត់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ**

**ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០**

**សម្ភាសន៍ដោយៈ សុខ វណ្ណៈ**

**០០:៥៤:២២**

**២២ទំព័រ**

វណ្ណៈ: ខ្ញុំឈ្មោះ សុខ វណ្ណៈនិងនេះឈ្មោះប៊ុន ផន ។

ចាន់ថូ : បាទ ។

វណ្ណៈ: ខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំបានមកដល់ស្រុកម៉ាឡៃគឺចង់ដឹងរឿងរ៉ាវដែលទាក់និងស្រុកម៉ាឡៃនិងចង់ដឹងប្រវត្តិពូខ្លះៗថា
កាលពីតូចពូរៀនសូត្របានត្រឹមណានិងឈប់រៀននៅ ឆ្នាំណា?

ចាន់ថូ : បាទ ។

វណ្ណៈ: ចឹងបទសម្ភាសន៍ខ្ញុំជាមួយពូហ្នឹង អាចអនុញ្ញាតឲ្យខ្ញុំយកទៅសរសេរបោះពុម្ពជាសៀវភៅបានទេ?

ចាន់ថូ : មានអី មិនអីទេ ។

វណ្ណៈ: ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

ចាន់ថូ : ខ្ញុំឈ្មោះ ផែត ចាន់ថូ ។

វណ្ណៈ: ពូអាយុប៉ុន្មានហើយ?

ចាន់ថូ : អាយុ៥៥ឆ្នាំ ។

វណ្ណៈ: ប្រពន្ធពូឈ្មោះអីដែរ?

ចាន់ថូ : ឈ្មោះទឹម ណាត ។

វណ្ណៈ: ចឹងពូមានកូនប៉ុន្មាននាក់?

ចាន់ថូ : កូន៥នាក់ សុទ្ធតែប្រុស ។

វណ្ណៈ	ចឹងពូមានស្រុកកំណើតនៅណា?

ចាន់ថូ	:	នៅស្រុកទ្រាំង ។

វណ្ណៈ	នៅភូមិអី?

ចាន់ថូ	:	នៅភូមិរវៀង ឃុំផ្ទុំ ស្រុកទ្រាំង ខេត្តតាកែវ ។

វណ្ណៈ	ចឹងរាល់ថ្ងៃនៅភូមិឃុំណា?

ចាន់ថូ	:	នៅភូមិវាលហាត់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

វណ្ណៈ	ចឹងមុខរបរសព្វថ្ងៃ?

ចាន់ថូ	:	ជាគ្រូបង្រៀន ។

វណ្ណៈ	ចឹងសូមឲ្យពូរៀបប្រវត្តិដែលពូធ្លាប់ឆ្លងកាត់យ៉ាងម៉េច?

ចាន់ថូ	:	កាលពីតូចខ្ញុំរៀននៅសាលាបឋមសិក្សាផ្ទុំហ្នឹងតែម្តង កាលនៅសាលាមធ្យមសិក្សាចប់ត្រឹមថ្នាក់ទី៧ ។

វណ្ណៈ	បាទ ។

ចាន់ថូ	:	ដល់ឆ្នាំប៉ុន្មានទេ ប្រេឡូងថ្នាក់ទី៣នៅឆ្នាំ១៩៧២ នៅវិទ្យាល័យតានីខេត្តកំពត ។

វណ្ណៈ	បាទ ។

ចាន់ថូ	:	ចឹងកំរិតវិជ្ជារបស់ខ្ញុំត្រឹមថ្នាក់ទី៣ចាស់ ។

វណ្ណៈ	បាទ ។

ចាន់ថូ	:	ឆ្នាំ៧២ហ្នឹងខ្ញុំនៅក្នុងរបបលន់ នល់នៅពេលនោះ តែនៅឆ្នាំ៧២ដដែលនេះមានខាងយៀកកុងវ៉ៃរបបលន់ នល់ហ្នឹងបែក ក្រោយពីបែកទៅក្រុមអាយៀកកុងហ្នឹងបានជម្លៀសពួកខ្ញុំឲ្យមកនៅជាមួយក្រុមកាលហ្នឹងគេមិនទាន់ហៅថាខ្មែរក្រហមទេ ។

វណ្ណៈ	ជម្លៀសប្រជាជនចេញ?

ចាន់ថូ	:	បាទ!ជម្លៀសប្រជាជនចេញមកក៏មកតាំងពីឆ្នាំ៧២មកដល់ឆ្នាំ៧៩ ។

វណ្ណៈ	ចឹងខាងចេញមកហ្នឹងនៅខាងណាវិញ?

ចាន់ថូ	:	កាលចេញមកនៅក្នុងខេត្តតាកែវដដែល គ្រាន់តែយើងចេញពីភូមិមកខាងលើៗដែលគេហៅថាតំបន់រំដោះនោះ នៅតំបន់ខាងយៀកកុងកាន់កាប់ ។

វណ្ណៈ	បាទ ។

ចាន់ថូ	:	ផ្តាច់ពីតំបន់ទាហានលន់ នល់ ។

វណ្ណៈ	ចឹងកាលដែលពូចេញមកពូមានចូលជាមួយចលនាខ្មែររំដោះទេ?

ចាន់ថូ	:	ជាធម្មតាកាលចូលមកហ្នឹងគេឲ្យយើងធ្វើឈ្លប ។

វណ្ណៈ ចឹងកាលធ្វើឈ្លបនៅឆ្នាំណា?

ចាន់ថូ ៖ និយាយរួមចាប់តាំងពីចេញមកហ្នឹង តាំងពី៧២មករហូតធ្វើឈ្លបនៅប្រចាំឃុំ៨មុំហ្នឹង តែឃុំហ្នឹងមិនរំដោះទាំងស្រុងទេ យើងឡើងទៅលើសម្រាប់ឃុំយើងចុះមកនៅឃុំដដែល ។

វណ្ណៈ បាទ ។

ចាន់ថូ ៖ បន្ទាប់មកទៀតបានឡើងឆ្នាំ៧៣-៧៤នេះបានឡើងមកកងទ័ពស្រុក ហើយមកទ័ពតំបន់មកភូមិភាគ ។

វណ្ណៈ ស្រុកណា?

ចាន់ថូ ៖ ស្រុកទ្រាំងដដែល ។

វណ្ណៈ កាលហ្នឹងភូមិភាគណា?

ចាន់ថូ ៖ ភូមិភាគនិរតី ។

វណ្ណៈ កាលហ្នឹងតំបន់ប៉ុន្មាន?

ចាន់ថូ ៖ តំបន់១៣ ។

វណ្ណៈ ចឹងគេហៅស្រុកប៉ុន្មាន?

ចាន់ថូ ៖ ស្រុក១០៧ ។

វណ្ណៈ ចឹងយ៉ាងម៉េចទៀត?

ចាន់ថូ ៖ រហូតមកដល់ឆ្នាំ៧៧ខ្ញុំត្រូវរបួសនៅព្រំដែនខាងកើត ។

វណ្ណៈ ចឹងកាលហ្នឹងវៃជាមួយយួន?

ចាន់ថូ ៖ បាទ! កាលហ្នឹងយើងរំដោះបាននៅឆ្នាំ៧៥ហើយណាស់ ។

វណ្ណៈ បាទ ។

ចាន់ថូ ៖ យើងរំដោះពីរបបលន់ នល់នេះនៅឆ្នាំ៧៥ដល់៧៧មានចលនាធំបានទៅវៃជាមួយយួនខាងត្បូង ។

វណ្ណៈ បាទ ។

ចាន់ថូ ៖ ដល់ត្រូវរបួសពេលហ្នឹងបានមកដេកពេទ្យនៅភ្នំពេញ១៧មេសា ។

វណ្ណៈ បាទ!ចឹងកាលហ្នឹងពូត្រូវរបួសនៅត្រង់ណា?

ចាន់ថូ ៖ កាលហ្នឹងត្រូវរបួសជើង ។

វណ្ណៈ ចឹងខ្ញុំចង់សួរកាលឆ្នាំ៧៥ពូឈ្នះចូលទីក្រុងភ្នំពេញហ្នឹងពូនៅកន្លែងណា?

ចាន់ថូ ៖ មិនបានចូលទេ ពេលដែលរំដោះហើយហ្នឹងចេញមកធ្វើផ្លូវថភ្លើងជួសជុលផ្លូវឡានៅពេលដែលសភាពការណ៍ដុនដាបជាមួយយួនហ្នឹងបានមកព្រំដែន ។

វណ្ណៈ  ចឹងកាលពូនៅជួសជុលផ្លូវរថភ្លើងពីឆ្នាំ៧៥ដល់៧៦ហ្នឹង  កាលហ្នឹងពីណាជាប្រធានធំនៅកន្លែងហ្នឹង?

ចាន់ថូ ៖ ខ្ញុំភ្លាប់មិនបានទេ ។

វណ្ណៈ  ចឹងមិនមែនវន វេតអីទេ?

ចាន់ថូ ៖ ទោះបីជាថា  វន  វេតយើងមិនដល់ព្រោះគេជាថ្នាក់កំពូល  ចឹងកាលហ្នឹងខ្ញុំអាយុប្រហែលជា ២០ជាង  ចឹងប្រធានកងតូចកងធំខ្លួនឯងសឹកថាមិនស្គាល់ច្បាស់ផង ។

វណ្ណៈ  បាទ ។

ចាន់ថូ ៖ ចឹងរហូតដល់ថ្នាក់កំពូលហ្នឹងរឹតតែលែងស្គាល់ហើយ ។

វណ្ណៈ  ចឹងកាលមុនវៃចូលទីក្រុងភ្នំពេញហ្នឹង  ពូនៅកងពលទីប៉ុន្មាន?

ចាន់ថូ ៖ ខ្ញុំនៅកងពលទី៣  ក្រោយមកគេដាក់១៦៤ ។

វណ្ណៈ  ចឹងកងពលទី៣ហ្នឹងពីណាជាអ្នកដឹកនាំ?

ចាន់ថូ ៖ ដូចជាតា  មុត ។

វណ្ណៈ  មាស  មុតហ្នឹង?

ចាន់ថូ ៖ តា  មុតកូនប្រសារតាម៉ុកនោះណាស់ ។

វណ្ណៈ  ចឹងតា  មុតក្រោយមកគាត់ទៅកាន់ខាងជើងទឹកវិញ?

ចាន់ថូ ៖ ហ្នឹងហើយផ្លាស់ពីកងពលហ្នឹងទៅ១៦៤ហ្នឹងនៅកំពង់សោម ។

វណ្ណៈ  ចឹងពូមានបានទៅដែរ?

ចាន់ថូ ៖ ខ្ញុំមិនបានទៅទេ  ព្រោះត្រូវរបួសបាត់ទៅហើយ  តែក្រោយមកខ្ញុំដឹងថាកងពលពួកខ្ញុំហ្នឹងគេបញ្ជូនទៅកំពង់សោមហើយដាក់ថាកងពល១៦៤វិញ  ចឹងខ្ញុំមិនបានទៅទេខាងផ្នែកជើងទឹកហ្នឹង ។

វណ្ណៈ  ចឹងពូទៅវៃជាមួយយួនដល់ឆ្នាំ៧៩តែម្តង?

ចាន់ថូ ៖ ទេ  កាលឆ្នាំ៧៧ខ្ញុំត្រូវរបួសមកដេកពេទ្យ  ដល់ចេញពីពេទ្យមកតា  ម៉ុកបញ្ជូនមកបាត់ដំបងតែម្តង  ចឹងអ្នកពិការទាំងអស់បញ្ជូនមកបាត់ដំបងនៅឆ្នាំ១៩៧៨ ។

វណ្ណៈ  ចឹងនៅឆ្នាំ១៩៧៨ហ្នឹងពូជាហើយ?

ចាន់ថូ ៖ ជាហើយ  ជាគ្រាន់តែដើររួចតែយើងមិនទាន់ធ្វើការអីបាន ។

វណ្ណៈ  ចឹងតា  ម៉ុកឲ្យពូមកខេត្តបាត់ដំបងហ្នឹង  គាត់ឲ្យធ្វើអីដែរ?

ចាន់ថូ ៖ ឲ្យមកបាត់ដំបងហ្នឹងមិនដឹងជាមកធ្វើអី  អ្នកពិការនៅតាខ្មៅហ្នឹងមកទាំងអស់មានច្រើនរយណាស់ ។

វណ្ណៈ បាទ ។

ចាន់ថូ ៖ មិនដឹងជាគោលបំណងមកធ្វើអី មកដល់ខេត្តបាត់ដំបងបានបែកក្រុមនេះនៅទីនោះមិនដឹងជាមានតួនាទីធ្វើអី ។

វណ្ណៈ ចឹងកាលពូនៅជាយុទ្ធជនហ្នឹងការហូបចុកលំបាកឬមិនលំបាកទេ?

ចាន់ថូ ៖ មានពេលខ្លះយើងពិបាកដែរ មានពេលខ្លះវាអត់ពិបាកទេវាចឹង ចឹងបានជានិយាយដល់បញ្ហាហ្នឹងកាលដែលខ្ញុំធ្វើជាគ្រូបង្ហាត់នៅការិយាល័យបោះឆ្នោតខេត្ត ។

វណ្ណៈ បាទ ។

ចាន់ថូ ៖ មានអនុបណ្ឌិតម្នាក់គាត់សួរខ្ញុំធ្វើការជាមួយគ្នា គាត់និយាយថារបបហ្នឹងល្អណាស់ ប៉ុន្តែគ្រាន់តែហូបមិនឆ្អែតហើយកាប់សម្លាប់បន្តិច ។

វណ្ណៈ បាទ ។

ចាន់ថូ ៖ សួរខ្ញុំបីបួនសារព្រោះមនុស្សធ្វើការជាមួយគ្នាយល់ចិត្តគ្នាណាស់ ។

វណ្ណៈ បាទ ។

ចាន់ថូ ៖ ដល់ថ្ងៃក្រោយខ្ញុំទ្រាំមិនបានខ្ញុំសួរវិញថា ឯងនៅណាកាលសម័យហ្នឹងសម័យ៣ឆ្នាំឯងនៅណាខ្ញុំនៅសហករណ៍ខ្ញុំនៅកងចល័ត តាមពិតខ្ញុំត្រូវសួរឯងវិញល្អជាង ។

វណ្ណៈ បាទ ។

ចាន់ថូ ៖ ព្រោះឯងនៅក្នុងអាហ្នឹង ព្រោះឯងដឹងហូបមិនគ្រប់ឯងដឹងវៃចោលឯងដឹងរបបនេះចេះចុះខ្ញុំនៅព្រំដែននោះ ដូច្នេះខ្ញុំមិនបានដឹងការអត់ឃ្លានរបស់ប្រជាជនយ៉ាងម៉េចទេ ។

វណ្ណៈ មែនខ្ញុំទទួលស្គាល់ថា ខាងទ័ពមិនបានដឹងទេ ។

ចាន់ថូ ៖ ដល់នេះគាត់ឆ្លើយថាតាឯងនេះឆ្លើយឆ្លាតណាស់ ខ្ញុំថាដាក់ស្តែងចឹងមែនឯងដល់អនុបណ្ឌិតហើយឯងគិតមើលទៅ ឯងនៅក្នុងហ្នឹងគួរតែគ្នាសួរឯងវិញថា ឯងស៊ីបបរឬមួយស៊ីបាយ ។

វណ្ណៈ បាទ ។

ចាន់ថូ ៖ ពេលនៅសហករណ៍ហ្នឹងប្រជាជនអត់យ៉ាងម៉េច កាប់សម្លាប់យ៉ាងម៉េចខ្ញុំមិនដែលឃើញទេ ។

វណ្ណៈ បាទ ។

ចាន់ថូ ៖ តែបើយើងជាយោធាគេថាយើងជាអ្នកកាប់សម្លាប់ហើយជាមួយខ្មាំងសត្រូវមិនចឹង ។

វណ្ណៈ បាទ ។

ចាន់ថូ ៖ ចឹងបានជាការហូបចុករបស់យោធានេះវាមានពេលអត់វាមានពេលមានចឹងដែរ ជួនការមានឧបស័គ្គយកទៅមិនដល់ចឹងវាអត់ដូចគ្នា ។

វណ្ណៈ បាទ ។

ចាន់ថូ ៖ តែបើអត់តាមសហករណ៍យ៉ាងម៉េចនោះខ្ញុំអត់មានបានដឹងទេ ធម្មតាទេសម័យនោះកាលណាយើងចេញទៅសមរភូមិហើយគេមិនឲ្យជួបបងប្អូនទេ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ចឹងបានជាបងប្អូនខ្ញុំ៧នាក់ ថានរណានៅណាខ្លះខ្ញុំមិនបានដឹងទេ ព្រោះទី១ខ្ញុំចេញទៅហ្នឹងជាអនុធនសិស្ស ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ចឹងខ្ញុំត្រូវតែលាក់ខ្លួនខ្ញុំដើម្បីរួចខ្លួន ខ្លួនខ្ញុំឪពុកម្ដាយបងប្អូនខ្ញុំមិនដឹង ទោះបីគេសួរក៏ខ្ញុំមិនប្រាប់ដែរ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ដើម្បីខ្ញុំការពារខ្លួនខ្ញុំ ទីចុងបំផុតខ្ញុំបានរួចជីវិតរាល់ថ្ងៃ មកពីខ្ញុំការពារខ្លួនខ្ញុំ តែទីចុងបញ្ចប់បានខ្ញុំដឹងថាបងប្អូនខ្ញុំសម័យនោះស្លាប់អស់ប្អូននាក់ ។

វណ្ណៈ៖ ចឹង?

ចាន់ថូ ៖ បាទ ។

វណ្ណៈ៖ ចឹងបងប្អូនពូស្លាប់ប្អូននាក់នៅក្នុងសម័យហ្នឹងដែរ?

ចាន់ថូ ៖ សម័យហ្នឹងឯង ឪពុកម្ដាយក៏ស្លាប់នៅក្នុងហ្នឹងដូចគ្នា ។

វណ្ណៈ៖ ចឹងបងប្អូនពូមានប៉ុន្មាននាក់?

ចាន់ថូ ៖ មាន៨នាក់ ឥឡូវនៅសល់តែប្អូន ។

វណ្ណៈ៖ ចឹងខ្ញុំចង់ស្គាល់ឈ្មោះឪពុកពូ?

ចាន់ថូ ៖ ឈ្មោះ ង៉ែត ខេង ។

វណ្ណៈ៖ ម្ដាយ?

ចាន់ថូ ៖ ម្ដាយឪ នូក ម្ដាយខ្ញុំតាមមើលស្លាប់នៅឆ្នាំ៧៧ តែឪពុកខ្ញុំស្លាប់ឆ្នាំ៨០ជាងតាមមើល ។

វណ្ណៈ៖ ចឹង?

ចាន់ថូ ៖ បាទ!ហ្នឹងដឹងតាមបងប្អូនប្រាប់មក បងប្អូនដែលស្លាប់ទាំងអស់ហ្នឹងជាអ្នក១៧មេសា ជម្លៀសចេញនៅឆ្នាំ៧៥ ។

វណ្ណៈ៖ ចឹងមានន័យថាបងប្អូនពូជនានលន់ នល់នៅភ្នំពេញ?

ចាន់ថូ ៖ ហ្នឹងហើយនៅភ្នំពេញ ចឹងបានជាខ្ញុំដឹងថាប្រវត្តិចឹងខ្ញុំទៅនោះហើយមិនត្រឡប់មកផ្ទះវិញទេ មិនវិលត្រឡប់មកស្គាល់ឪពុកម្ដាយបងប្អូនវិញទេ ដើម្បីយើងលាក់ប្រវត្តិរូបខ្លួនយើងកុំឲ្យគេថាបងប្អូននៅខាងនេះខាងនោះ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ទទួលយើងកាលហ្នឹងជាអនុធនសិស្សទៀត ចឹងគេកំពង់តែតាមដាន ចឹងខ្ញុំការពារខ្លួនខ្ញុំរហូតដល់រាល់ថ្ងៃ ។

វណ្ណៈ៖ ចឹងក្រោយមកពូបានទៅលេងស្រុកបានដឹង?

ចាន់ថូ ៖ បាទ! នៅឆ្នាំ៩៣ខ្ញុំទៅលេងស្រុកបានខ្ញុំដឹង កាលហ្នឹងសម័យអ៊ុនតាក់ណាស់ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ទៅលេងស្រុកបានតែមួយយប់ទេ ។

វណ្ណៈ៖ ចឹងរហូតមកដល់ពេលនេះពូទៅលេងស្រុកបានប៉ុន្មានដង?

ចាន់ថូ ៖ បើស្រុកកំណើតខ្ញុំមិនដែលបានទៅទេ តែស្រុកកំណើតប្រពន្ធខ្ញុំទៅក្នុងមួយឆ្នាំ៣ទៅ៤ដងឯនោះ ព្រោះខ្ញុំទៅរៀននៅភ្នំពេញមួយឆ្នាំប៉ុន្មានដងខ្ញុំទៅទាំងប៉ុណ្ណឹងដង ស្រុកប្រពន្ធនៅខាងព្រៃកប្បាសណាស់ តែស្រុកខ្ញុំនៅខាងត្បូងតាកែវនេះខ្ញុំមិនដែលបានទៅទេ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ព្រោះអីទៅយ៉ាងម៉េចបើបងប្អូនចេញពីហ្នឹងអស់ហើយនៅតែជីដូនមួយទេ មិនមែនជារឿងអីទេ តែខ្ញុំខ្ជិលទៅ បើទៅមិនដឹងជាស្គាល់ពីណា ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ចឹងបើខ្ញុំនិយាយពីប្រវត្តិរបស់ខ្ញុំ ទោះបីជាខ្ញុំតស៊ូក្នុងរបបនោះក៏ខ្ញុំត្រូវការលាក់ខ្លួនដើម្បីសុវត្ថភាពរបស់ខ្ញុំដែរ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ បើខ្ញុំមិនចឹងក៏ខ្ញុំមិនអាចមានជីវិតមកដល់រាល់ថ្ងៃដែរ ហើយក៏មិនអមអរសាទរថារបបហ្នឹងវាអស្ចារ្យនោះទេ តាមពិតគោលបំណងខ្ញុំរៀនខ្ញុំមិនចង់បានទេ របបអស់ហ្នឹង ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ តែទទួជាអកុសលគេរើកន្លែងហ្នឹងបែកហើយបើមិនចេញក៏ត្រូវតែចេញ បើមិនកាន់កាំភ្លើងក៏ត្រូវតែកាន់កាំភ្លើង ចឹងបានជាប្រាប់កូនខ្ញុំរាល់ថ្ងៃថា បើចង់ធ្វើប៉ូលីស ប៉េអឹមគឺប៉ាមិនឲ្យកូនឯងធ្វើទេ បើធ្វើការផ្សេងអីធ្វើទៅ ព្រោះអញឆ្អែតហើយ ។

វណ្ណៈ៖ ចឹងខ្ញុំចង់សួរបកទៅវិញថា កាលហ្នឹងខាងកងទ័ពនិងកម្មករនៅភ្នំពេញតែងតែមិនបានដឹងឪពុកម្ដាយបងប្អូននៅខាងក្រោយទេ លុះត្រាតែអ្នកហ្នឹងសុំបានមកលេងផ្ទះ តែខាងអង្គការគេកម្រឲ្យមកលេងណាស់ ។

ចាន់ថូ ៖ ដូចខ្ញុំនិយាយចឹង ខ្ញុំនៅទ័ពខាងព្រំដែនហ្នឹងទោះបីជាខ្ញុំសុំមកក៏គេមិនឲ្យមកដែរ ចឹងខ្ញុំនឹកឃើញខ្លួនឯងថា ខ្ញុំមិនសុំមកទេ បើខ្ញុំបានមកវិញខ្ញុំពិតជាដឹងប្រវត្តិក្រុមគ្រួសាររបស់ខ្ញុំហ្នឹងអ្នកនៅក្នុងរបបហ្នឹងច្រើន ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ដល់យើងមកដល់មានកុហក់គេយ៉ាងម៉េចបើយើងមកដល់ផ្ទះហើយ ចឹងបានជាខ្ញុំគិតថាខ្ញុំមិនសុំមកលេងផ្ទះទេ ដើម្បីកុំឲ្យដឹង ។

វណ្ណៈ៖ ចឹងបើមកខ្លាចឃើញមិនល្អគេតាមដានទៀត?

ចាន់ថូ ៖ បាទ!វាចឹងចុះបើគេសួរថាបងប្អូននៅណាខ្លះ ហើយយើងថាមិនដឹងគឺមិនកើតទេ តែបើយើងមិនមកគេសួរថាបងប្អូននៅណាខ្លះ? ខ្ញុំថាមិនដឹងទេ ខ្ញុំចេញតាំងពីឆ្នាំ៧២មកខ្ញុំមិនដែលបានទៅផ្ទះខ្ញុំមិនបានដឹងទេ តែយើងបានដឹងទៅហើយ ។

វណ្ណៈ៖ ចឹងខ្ញុំចង់ដឹងថា សម្ភារៈយោធាដែលពូទទួលបានតាំងពីឆ្នាំ៧២រហូតដល់ឆ្នាំ៧៥និងនៅពេលវៃជាមួយយួនទៀត ពូមានដឹងថាសម្ភារៈមកពីខាងណាទេ?

ចាន់ថូ ៖ សម្ភារៈហ្នឹងមានភាគច្រើនជារបស់មកពីចិន សូម្បីតែមកដល់ឆ្នាំនេះហើយក៏ជារបស់ចិនដដែលចឹងសុទ្ធតែរបស់ចិន ។

វណ្ណៈ៖ ចឹងកាលដែលវៃនៅព្រំដែនហ្នឹងមានស្លាប់រស់ជារឿងធម្មតា?

ចាន់ថូ ៖ ហ្នឹងហើយ ។

វណ្ណៈ៖ ចឹងខ្ញុំចង់សួរផាកមកខាងខេត្តបាត់ដំបងវិញ នៅពេលដែលវៀតណាមវៃចូលមកហេតុអីបានជាពូមិនរត់ទៅរកស្រុកកំណើតបែរជារត់មកព្រំដែនថៃវិញ?

ចាន់ថូ ៖ ខ្ញុំសូមនិយាយប្រវត្តិហ្នឹងបន្តិចកាលឆ្នាំ៧៨ ខែ៨ ខ្ញុំមកនៅបាត់ដំបង តា ម៉ុក ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ព្រោះអីកាលឆ្នាំ៧៧ខ្ញុំត្រូវរបួស ហើយខ្ញុំជារបួសខ្ញុំមិនទាន់បានមកខេត្តបាត់ដំបងទេ ខ្ញុំចូលមន្ទីរពិការនៅតា ខ្មៅ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ចឹងមន្ទីរពិការភូមិភាគគឺនៅតាខ្មៅ ចាប់ពីតាខ្មៅរហូតដល់ព្រែកហូរនៅម៉ាដ្ឋហ្នឹងគេហៅថាជាមន្ទីរ២០១ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ មន្ទីរ២០១ជាមន្ទីរពិការភូមិភាគនិរតី នៅឆ្នាំ៧៨ ប្រហែលជាខែ៩បានតា ម៉ុកប្រមូលអ្នកពិការហ្នឹងប្រហែលជា៤០០នាក់ យកមកនៅទីក្រុងបាត់ដំបងទាំងអស់ ។

វណ្ណៈ   បាទ ។

ចាន់ថូ :  ចឹងនៅបាត់ដំបងបានជាកន្លះខែបានគាត់ចាត់ចែងខ្លះទៅនៅសំ ឡូតខ្លះទៅនៅបវេលខ្លះទៅនៅនេះទៅនោះឲ្យគ្រប់កន្លែងក្នុងមួយកន្លែង១៨នាក់ចឹងទៅ ដោយឡែកតែខ្ញុំគេឲ្យនៅក្នុងខេត្តបាត់ដំបង ។

វណ្ណៈ   ចឹងនៅឆ្នាំ១៩៧៨ហ្នឹងអ្នកពិការយកមកពីតាខ្មៅទាំងអស់?

ចាន់ថូ :  បាទ!យកមកទាំងអស់ វាមិនអស់ទេ តែយកមកភាគច្រើនប្រហែលជា៨០០នាក់ប៉ុណ្ណឹង ។

វណ្ណៈ   ចឹងតាម៉ុក បែងចែកឲ្យទៅតាមស្រុក?

ចាន់ថូ :  ទៅតាមស្រុកឬតាមសហករណ៍ផ្សេងៗឬក៏តាមក្រសួងមន្ទីរផ្សេងៗទៀត គ្រប់កន្លែង ។

វណ្ណៈ   ចឹងកាលពូនៅបាត់ដំបងនៅតំបន់ប៉ុន្មាន?

ចាន់ថូ :  ខ្ញុំនៅទីក្រុងបាត់ដំបងតែម្ដង ។

វណ្ណៈ   នៅក្នុងតំបន់៣?

ចាន់ថូ :  មិនដឹងជាតំបន់ប៉ុន្មាន មិនដឹងជាតំបន់៣ឬតំបន់៤មិនដឹងត្រង់ហ្នឹង ព្រោះកាលហ្នឹងមកដល់ប្រហែលជាកន្លះខែរៀបចំរៀបគ្រួសារ ។

វណ្ណៈ   ចឹងពូរៀបគ្រួសារនៅឆ្នាំ៧៨ហ្នឹង?

ចាន់ថូ :  បាទ!នៅឆ្នាំ៧៨ហ្នឹង និយាយរួមអ្នកពិការទាំងប៉ុន្មានមុនហ្នឹងចេញទៅតាមកន្លែងត្រូវរៀបគ្រួសារទាំងអស់ ។

វណ្ណៈ   ចឹងកាលហ្នឹងមានប៉ុន្មានគូរ?

ចាន់ថូ :  ខ្ញុំកាលហ្នឹងតិចជាងគេទេ មានគ្នាតែ១២នាក់ ។

វណ្ណៈ   ចឹងមាន១២គូរ?

ចាន់ថូ :  បាទ!១២គូរហើយគ្រួសារខ្ញុំជារៀបចំភ្ញៀវនៅបាត់ដំបងជាអ្នកទទួលភ្ញៀវ ។

វណ្ណៈ   កាលហ្នឹងយើងស្រឡាញ់ស្នើអង្គការឬមួយយ៉ាងម៉េច?

ចាន់ថូ :  អត់ទេ កាលហ្នឹងអាយុ២៣ឆ្នាំ មិនទាន់នឹកឃើញស្រឡាញ់ដងហ្នឹង នឹកឃើញតែសុវត្ថភាពខ្លួនឯងតែមួយមុខទេ អត់មាននឹកឃើញស្រឡាញ់ទេ ព្រោះកាលនោះយើងដឹងហើយការស្រឡាញ់មិនទាន់មានអីហ្នឹងគ្នាក៏មានបញ្ហាដែរ ។

វណ្ណៈ   បាទ ។

ចាន់ថូ :  ចឹងខ្ញុំអត់មាននឹកឃើញរឿងស្រឡាញ់អ្នកណាម្នាក់ទេ តែគេរៀបចំហើយគេគ្រាន់តែប្រាប់ថា១២នាក់នេះ ទៅរៀបចំគូរស្រករនៅកន្លែងភ្ញៀវនៅកន្លែងសាលាខេត្តណាស់ នៅកន្លែងស្ពាន

ចាស់ហ្នឹង កន្លែងហ្នឹងជាកន្លែងទទួលភ្ញៀវបរទេស គ្រួសារខ្ញុំនៅកន្លែងទទួលភ្ញៀវហ្នឹងឯង ខ្ញុំមកទៅរៀបចំធម្មតាមិនដែលបានឃើញគ្នាផង ។

វណ្ណៈ: ចឹងនៅក្នុងកម្មវិធីហ្នឹងមានពីណាជាអ្នករៀងចំចូលរួមជាគណៈអធិបតី?

ចាន់ថូ : ខ្ញុំមើលទៅដូចជាគ្មានពីណាទេ មានតែប្រធានក្រុមដែលគេទទួលខុសត្រូវនៅកន្លែងទទួលភ្ញៀវហ្នឹងទេ អត់មានរៀបចំអីធំដុំទេ ។

វណ្ណៈ: តាមខ្ញុំដឹងខ្លះៗថានៅបាត់ដំបងមានតែតំបន់៣មួយទេ ដែលប្រជាជនមានហូបចុកគ្រប់គ្រាន់ ព្រោះអីខ្ញុំធ្លាប់សម្ភាសន៍តា ញឹកលី គាត់សម័យនោះគាត់ជាគណៈឃុំអូរដំបង ខ្ញុំបានជួបគាត់ហើយបានជួបប្រជាជនថាគាត់មិនឲ្យប្រជាជនហូបខ្វះខាតទេ តែសហករណ៍ផ្សេងមានមនុស្សស្លាប់ច្រើនមែន ខ្ញុំសួរប្រជាជនដែលធ្លាប់រស់នៅជាមួយគាត់កាលសម័យខ្មែរក្រហមនោះថាពិតជាចឹងមែន ។

ចាន់ថូ : បាទ!ចឹងបានថានៅក្នុងសហករណ៍រៀងហូបចុកអីដូចខ្ញុំបានជំរាបចឹងមិញហ្នឹង ខ្ញុំចេញពីអង្គភាពទាហានមកនៅកន្លែងហ្នឹងក៏ដូចជាអង្គភាពមួយដែរ មិនមានជាសហករណ៍អីហូបបាយធម្មតានៅកន្លែងភ្ញៀវ ។

វណ្ណៈ: បាទ ។

ចាន់ថូ : ហូបបាយធម្មតាមិនមានអីទេ ចឹងបានថារកកន្លែងហូបបបរកន្លែងលំបាកអីមិនឃើញ ។

វណ្ណៈ: បាទ ។

ចាន់ថូ : តែខ្ញុំជឿថាមានកន្លែងផ្សេងលំបាកហើយ ។

វណ្ណៈ: បាទ ។

ចាន់ថូ : ព្រោះខ្ញុំឮសូរគេនិយាយគ្រប់គ្នាថាចឹង ។

វណ្ណៈ: ចឹងពូកាលហ្នឹងមានជឿថាជំនាន់ខ្មែរក្រហមមានការសម្លាប់មនុស្សទេ?

ចាន់ថូ : ខ្ញុំមិនឃើញក៏ខ្ញុំត្រូវតែជឿ ទីមួយការហូបមិនគ្រប់គ្រាន់មិនឃើញក៏ត្រូវតែជឿ ព្រោះសឹងតែមួយរយភាគរយទៅហើយដែលគេនិយាយពាក្យហ្នឹង ទោះជាខ្ញុំមិនឃើញក៏ខ្ញុំជឿ ។

វណ្ណៈ: បាទ ។

ចាន់ថូ : ការសម្លាប់មនុស្សក៏មាន ហូបបបរបាយមិនគ្រប់ក៏មានចឹងរបបហ្នឹងជឿមិនអាចបដិសេធបានទេ ។

វណ្ណៈ: កាលហ្នឹងទោះពូជាយោធា តែពូក្រោយមកក៏អាចដឹងខ្លះៗបានដែរ ដោយសារជំនាន់ខ្មែរក្រហមមេធំៗមួយចំនួនក៏ត្រូវចាប់ខ្លួនដោយចោទថាក្បត់ ខ្មែរក្រហមចាប់ខ្មែរក្រហម?

ចាន់ថូ ៖ ត្រង់ហ្នឹងហើយដែលខ្ញុំការពារខ្លួនឯងនោះ ព្រោះខ្ញុំនៅជាមួយមេខ្ញុំនៅ២០១ហ្នឹងគេចាប់មេខ្ញុំ មេខ្ញុំពីរនាក់ដែលនៅមន្ទីរពិការហ្នឹងចាប់យកទៅទាំងពីរ ហើយខ្ញុំនៅផ្ទាល់ជាមួយគាត់ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ខ្ញុំជាពេទ្យរបស់គាត់ទៀត ព្រោះតាំងចេញមកខ្ញុំធ្វើពេទ្យយោធាហ្នឹងរហូតទៅ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ និរសាក៏គេចាប់ដោយឡែកតែខ្ញុំទេ តែគេមិនចាប់ក៏គេដកបញ្ឈប់ជើងចោលដែរ ។

វណ្ណៈ៖ ចឹងពូជាយោធាផ្នែកពេទ្យ?

ចាន់ថូ ៖ បាទ!ប្រចាំកងវរៈ ។

វណ្ណៈ៖ កងវរៈប៉ុន្មាន?

ចាន់ថូ ៖ កាលហ្នឹងតំបន់គេហៅ«ត៧» តែក្រោយមកវាភ្លេចអស់ទៅដល់មកដល់ភូមិភាគមិនដឹងជាប៉ុន្មានអីប៉ុន្មាន ។

វណ្ណៈ៖ ចឹងកាលហ្នឹងពូជាអ្នកចេះដឹងមួយដែរតែមិនមានអី?

ចាន់ថូ ៖ បាទ!មិនអីទេ ។

វណ្ណៈ៖ ជំនាន់ហ្នឹងពេទ្យ៦មករាច្រើនតែពេទ្យក្មេងៗមិនសូវជាចេះអក្សរផង ក៏ធ្វើពេទ្យបានដែរ ។

ចាន់ថូ ៖ កាលខ្ញុំមកដេកពេទ្យហ្នឹងខ្ញុំស្គាល់ពេទ្យ១៧មេសា ៦មករា ពេទ្យ៩៨ខ្ញុំស្គាល់ទាំងអស់ហ្នឹងកាលសម័យហ្នឹងស្គាល់ច្រើន ។

វណ្ណៈ៖ ចឹងពេទ្យយោធាព្យាបាលតែកងទ័ពសុទ្ធឬមួយយ៉ាងម៉េច?

ចាន់ថូ ៖ យើងចុះទៅជាមួយយោធា តែបើពេទ្យនៅមន្ទីរយោធាតែម្តងគេមានមន្ទីរដូចជា«៣៩៨» របស់កម្មករដូចជាពេទ្យ៦មករាចឹង អាហ្នឹងគេនៅខាងក្រោយទេ បើពេទ្យយោធាដូចថាយោធាឡើងច្បាំងហ្នឹងយើងនៅ២ទៅ៣គីឡូរកន្លែងច្បាំងហ្នឹង បើមានអ្នកត្រូវរបួសទៅយើងយើងធ្វើការរុំរបួសដើម្បីបញ្ជូនមកខាងក្រោយ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ចឹងទេ របៀបជាស្ថានទេយើងមិនមានកន្លែងសម្រាប់ព្យាបាលទេ ។

វណ្ណៈ៖ ចឹងខ្ញុំចង់សួរផាកមកវិញ កាលឆ្នាំ៧៩ពូរត់ចេញពីណា?

ចាន់ថូ ៖ ខ្ញុំរត់ចេញពីបាត់ដំបងមកដល់ស្រុកថៃ ។

វណ្ណៈ៖ ចឹងកាលរត់ចេញមកមានគ្នាច្រើនទេ?

ចាន់ថូ ៖ មានមនុស្សរាប់សែននាក់ពេលចេញមកហ្នឹង ។

វណ្ណៈ៖ កាលហ្នឹងខ្លាចយួន?

ចាន់ថូ : បាទ! ហើយមិននឹកឃើញថាមានគ្នាយើងរហូតដល់រាល់ថ្ងៃទេ ចឹងគ្មានណាចង់មកនៅកន្លែងនេះទេ មកទីនេះអត់មានឃើញថ្ងៃទេ ហើយមិនមានពីណាហ៊ានដេកថ្ងៃទេ ពេលនោះខ្ញុំពីរនាក់គ្រួសារមានអង្គរស្តាយម្នាក់ៗចឹងទៅ ។

វណ្ណៈ: ចឹងពូចំណាយពេលប៉ុន្មានបានរត់មកដល់ហ្នឹង?

ចាន់ថូ : ចំណាយពេលកន្លះខែ កាលហ្នឹងចេញមកពីសំឡូត កាលហ្នឹងយើងមិនដឹងផ្លូវយើងចេញពីសំឡូតមកដល់ប៉ៃយហ្នឹងដល់ឡាក់៦៩ហ្នឹងកន្លែងជីកត្បូងនោះណាស់ យើងចេញពីសំឡូតមកឡើងភ្នំចុះភ្នំគេថាដល់ប៉ៃយកន្លែងជីកត្បូងឲ្យថៃនោះ រួចជីកត្បូងនៅប៉ៃលិនទៀតគេហៅឡាក់៦៩នោះ យើងមិនដឹងផ្លូវទេដាក់ត្រីវិស័យឲ្យតែឃើញខាងលិចគឺដើរតម្រង់មកកន្លែងហ្នឹងប៉ះអីក៏យើងមិនដឹងដែរ ។

វណ្ណៈ: ចឹងចេញពីបាត់ដំបងមកដល់ថៃកន្លះខែ?

ចាន់ថូ : បាទ ។

វណ្ណៈ: ចឹងកន្លះខែហ្នឹងដើរកាត់ព្រៃរហូត?

ចាន់ថូ : ដើរកាត់ព្រៃរហូតយប់ឡើងដាំបាយហូបបាយហើយដេកព្រលឹមឡើងដាំបាយហូបហើយចេញដើរមកទៀត ។

វណ្ណៈ: ជាមួយប្រពន្ធពូហ្នឹង?

ចាន់ថូ : បាទ ។

វណ្ណៈ: ចឹងមានមនុស្សផ្សេងជាច្រើននាក់?

ចាន់ថូ : បាទ! មានមនុស្សផ្សេងរាប់សែននាក់ ។

វណ្ណៈ: ចឹងនៅពេលទៅដល់ស្រុកថៃហើយហេតុអីក៏ពូមិនមានបំណងចេញទៅស្រុកក្រៅបន្តបែរជាមកធ្វើចលនាប្រឆាំងជាមួយទាហានយួនតទៅទៀត?

ចាន់ថូ : ពេលដែលខ្ញុំទៅដល់ស្រុកថៃប្រជាជនទាំងអស់ដែលមានរាប់សែននាក់ហ្នឹង ថៃវាប្រមូលឲ្យទៅនៅវត្តមួយក្នុងវត្តទាំងអស់គ្នាហ្នឹងឲ្យតែនៅក្នុងវត្ត ថៃវាដឹកបាយដឹកចំណីមកឲ្យហូបធម្មតាដល់ហ្នឹងបានហូបស្រួលហើយតែបានតែមួយថ្ងៃពីរថ្ងៃទេ រួចហើយបានឡានវាប្រហែលជា២០ទៅ៣០គ្រឿងដឹកយើងពីហ្នឹងមកចុះនៅខ្សែមនេះ ។

វណ្ណៈ: ចឹងដឹកយើងចេញពីថៃមកវិញ?

ចាន់ថូ : បាទ! ដឹកតាមផ្លូវថៃតែមកចុះនៅបន្ទាយខ្សែមនេះ កន្លែងគ្រាន់កន្លែងកំរៀងនោះដើម្បីឲ្យយើងចូលមកដីយើងវិញ ។

វណ្ណៈ: បាទ ។

ចាន់ថូ ៖ ចឹងនៅពេលដែលចូលដីខ្មែរហើយពួកខ្ញុំក៏ចាប់ផ្ដើមដើរថ្មើរជើងចាប់ពីហ្នឹងមករហូតមកដល់ហ្នឹងមកដល់នៅឆ្នាំ៨០ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ឆ្នាំ៨០ប្រហែលជាខែ៦-៧ មិនមែនឆ្នាំ៨០ទេ ឆ្នាំ៧៩ ។

វណ្ណៈ៖ ចឹងឆ្នាំណា?

ចាន់ថូ ៖ ឆ្នាំ៧៩ប្រហែលជាខែ៦ ។

វណ្ណៈ៖ ចឹងកងកំលាំងខ្មែរក្រហមចាប់ផ្ដើមប្រមូលផ្ដុំកំលាំងវិជាមួយយួននៅពេលណា?

ចាន់ថូ ៖ ចឹងកាលហ្នឹងខ្ញុំជាប្រជាជនធម្មតាវិញ ឯទាហានគេរៀបចំយ៉ាងម៉េចខ្ញុំលែងដឹងហើយ ។

វណ្ណៈ៖ ចឹងពូមានប្រពន្ធកូនហើយជាប្រជាជន?

ចាន់ថូ ៖ បាទ! រួមទាំងអស់ជាប្រជាជន ឯក្រុមទាហានគេរៀបចំផ្សេងទៀតអាហ្នឹងមិនដឹងជាគេរៀបចំរបៀបណាទៅទប់ទល់ទៅខាងមុខអាហ្នឹងខ្ញុំមិនដឹងទេ ខ្ញុំគិតពីតែរឿងរួចខ្លួនប៉ុណ្ណឹងទេ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ នៅឆ្នាំ៧៩ដែរ ប្រហែលជាខែតុលាខ្ញុំចូលទៅជំរំស្រះកែវ ប្រហែលជាខែ១០ខ្ញុំទៅជំរំស្រះកែវ ស្រះកែវបើគិតពីនេះទៅប្រហែលជាពាក់កណ្ដាលបាងកកឆ្ងាយណាស់ ។

វណ្ណៈ៖ ចឹងខែ១០នៅឆ្នាំ៧៩ដដែល ។

ចាន់ថូ ៖ បាទ!ខែ១០ឆ្នាំ៧៩ ។

វណ្ណៈ៖ ចឹងហេតុអីបានជាពូត្រឡប់ទៅនៅជំរំម្ដងទៀត?

ចាន់ថូ ៖ កាលនោះនៅកន្លែងហ្នឹងស្លាប់ច្រើនពេក ហើយកាកក្របាតមិនទាន់ចូលមកដល់ចែកអីទេ ពេលនោះអត់ឃ្លានណាស់ ខែ៨ទៅ៩នៅទីនេះ គ្រុនចាញ់ស្លាប់ខ្លាំងណាស់ អត់ឃ្លានក៏ខ្លាំងដែរ ចឹងមានខាងកាកបាទក្រហមដឹកយើងយកទៅជំរំមួយគេហៅថាជំរំស្រះកែវហើយគេហៅថា ជាជំរំខ្មែរក្រហមគេហៅបានពីរចឹង ។

វណ្ណៈ៖ ចឹងយ៉ាងម៉េចទៀតទៅ?

ចាន់ថូ ៖ នៅក្នុងជំរំហ្នឹងហើយ ខ្ញុំនិយាយពីប្រវត្តិរបស់ខ្លួនខ្ញុំពេលយើងនៅក្នុងជំរំអង្គការមនុស្សធម៌ហ្នឹងគេរៀបយើងឡូៗហ្នឹងមានម៉ារីយ៉េដូចជាទាហានហ្នឹង ដោយគេឲ្យឫស្សីយើងឲ្យស្លឹកយើងសម្រាប់ធ្វើជាបន្ទប់ៗចឹងទៅ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ហើយគេបែងចែកជាឡូ មួយឡូហ្នឹងមាន៣ទៅ៤អាគារក្នុងមួយអាគារហ្នឹងមានពី៣០ទៅ៤០គ្រួសារ ។

វណ្ណៈ  បាទ ។

ចាន់ថូ ៖ ហើយបីឡូគេត្រូវបង្កើតជាសន្មាត់មួយ  នៅពេលនោះត្រូវគេរៀបចំឲ្យធ្វើជាប្រធានឡូដែលទទួលខុសត្រូវបីអាគារឬ៤អាគារហ្នឹង ហើយខ្ញុំក៏ធ្វើជាគ្រូបង្រៀនចាប់ពីពេលនោះមកដែរ ។

វណ្ណៈ  បាទ ។

ចាន់ថូ ៖ ខ្ញុំរៀនខ្លួនឯងជាភាសាអង់គ្លេសហើយខ្ញុំក៏បង្រៀនបងប្អូនជាភាសាខ្មែរទៀត ។

វណ្ណៈ  ចឹងពូធ្វើជាគ្រូបង្រៀននៅស្រះកែវ?

ចាន់ថូ ៖ បាទ ។

វណ្ណៈ  ចឹងបន្ទាប់មកទៀតពូចូលមកនៅម៉ាឡៃវិញឬយ៉ាងម៉េច?

ចាន់ថូ ៖ ខ្ញុំចង់និយាយថានៅឆ្នាំ៨០ហ្នឹង  អ្នកដែលរៀនអង់គ្លេសជាមួយគ្នាហ្នឹងមាន៣០នាក់ហ្នឹង  គ្រូបរទេសហ្នឹងបានសួរយើងថា  មានអ្នកណាស្ម័គ្រចិត្តទៅប្រទេសទី៣  ព្រោះអ្នករៀនជាមួយគ្នាហ្នឹងគេធ្លាប់លំបាកនៅក្នុងស្រុកចឹងគេអត់នៅទេ  ចឹងគេចេញទៅក្រៅ  ដោយឡែកតែខ្ញុំនេះកាលទៅស្រុកគេនេះខ្លាចមិនបានចូលស្រុកខ្លួនឯងវិញ  មិនមែននឹកឃើញដូចរាល់ថ្ងៃនេះថាអ្នកដែលទៅមានសំណាងទេ ។

វណ្ណៈ  បាទ ។

ចាន់ថូ ៖ ហើយខ្ញុំជាសិស្សច្បងមុនគេ ជាង៣០នាក់គេទៅរហូតដល់រាល់ថ្ងៃ ដោយឡែកតែខ្ញុំថាមិនទាន់អស់កម្មត្រឡប់មកវិញ ។

វណ្ណៈ  ចឹងកាលហ្នឹងត្រឡប់មកតែពូទេ?

ចាន់ថូ ៖ បាទ!  មកដំបូងនៅគីឡូ១៣ទេ  អត់មានធ្វើអីទេ ។

វណ្ណៈ  គីឡូ១៣ហ្នឹងនៅណា?

ចាន់ថូ ៖ នៅស្រុកសំពៅលូនរាល់ថ្ងៃនេះ ។

វណ្ណៈ  ចឹងនៅសំពៅលូនប្រហែលជាប៉ុន្មានឆ្នាំបានមកដល់នេះ?

ចាន់ថូ ៖ រហូតមកដល់ឆ្នាំ៨៤ ។

វណ្ណៈ  ចឹងឆ្នាំ៨៤ចូលដល់ម៉ាឡៃ ។

ចាន់ថូ ៖ អត់ទេ  ឆ្នាំ៨៤ហ្នឹងទាហានខាងក្នុងបើកយុទ្ធនាការវ៉ៃដាច់ព្រំដែនហើយ  ចឹងពេលនោះចូលទៅដីថៃទៅនៅជំរំសាយអេកនោះម្តងទៀត  កាលឆ្នាំ៨៤វ៉ៃខ្លាំងណាស់  ម៉ាដូរនេះវ៉ៃដាច់ទាំងអស់ចឹងប្រជាជនពីនេះទៅដល់នោះរត់ទៅធ្លាក់ដីថៃទាំងអស់  នៅពេលដែលចូលជុំរំសាយអេកហ្នឹងខ្ញុំធ្វើជាគ្រូបង្រៀនដដែល ។

វណ្ណៈ  ចឹងចូលដីថៃវិញ?

ចាន់ថូ ៖ បាទ! ចឹងនៅឆ្នាំ៨៥ចេញពីជំរំសាយអេកខ្ញុំចេញទៅជំរំរបស់ខ្មែរក្រហមដែលជួលដីថៃនៅប្រហែលជា១០គីឡូពីនេះទៅគេហៅថា "ឈុំថង" ។

វណ្ណៈ៖ ចឹងនៅឈុំថងហ្នឹងដីថៃ?

ចាន់ថូ ៖ ហ្នឹងហើយដីថៃនៅជាប់ភូមិថៃជាមួយថៃទាំងអស់នៅហ្នឹងរហូតដល់ឆ្នាំ៩១បានខ្ញុំចូលមកដល់ទីនេះ តែនៅនោះក៏ខ្ញុំជាគ្រូបង្រៀនដដែល ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ទៅកន្លែងណាបង្កើតសាលាកន្លែងហ្នឹង ។

វណ្ណៈ៖ ចឹងមកដល់ស្រុកម៉ាឡៃនៅឆ្នាំ៩១?

ចាន់ថូ ៖ បាទ ។

វណ្ណៈ៖ ចឹងកាលសម្តេចចុះមកផ្តល់សារតាំងពូមិនបានដឹងទេ?

ចាន់ថូ ៖ កាលសម្តេចចុះមកនៅឆ្នាំ៨០ជាង ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ កាលឆ្នាំ៨០ជាងខ្ញុំនៅខាងត្បូងនេះទេ តែកាលហ្នឹងខ្ញុំដឹងថាសម្តេចមកទីនេះ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ មកធ្វើសារតាំងនៅទីនេះ តែគ្រាន់តែផ្នែកពីរហ្នឹងវាផ្សេងគ្នា នៅទីនេះគេហៅថាតំបន់១០២នៅម៉ាឡៃនេះ ហើយខាងត្បូងនោះគេហៅថាតំបន់៣២ ខាងសំពៅលូននោះ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ចឹងអ្នកទាំងតំបន់ហ្នឹងអ្នកទទួលខុសត្រូវផ្សេងគ្នា ។

វណ្ណៈ៖ ចឹងតំបន់៣២ហ្នឹងយើងដាក់នៅពេលណា?

ចាន់ថូ ៖ តំបន់ហ្នឹងយើងដាក់ជំនាន់ខ្មែរក្រហមនៅឆ្នាំ៨០ហ្នឹង ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ កន្លែងហ្នឹងជាកន្លែងប្រកអន្តរជាតិ ។

វណ្ណៈ៖ ចឹងកន្លែងនេះជំនាន់ប៉ុល ពតមិនដឹងថាមានតំបន់អីទេ?

ចាន់ថូ ៖ មិនមានទេ គឺព្រៃទាំងអស់កាលខ្ញុំមកឆ្នាំ៧៩ហ្នឹងមើលថ្ងៃមិនឃើញទេ សុទ្ធតែព្រៃទាំងអស់ដល់ចាប់ពីឆ្នាំ៩១មកនៅកន្លែងនេះដល់រាល់ថ្ងៃហើយក៏នៅជាគ្រូបង្រៀនរហូតដល់រាល់ថ្ងៃដែរ ។

វណ្ណៈ៖ ចឹងនៅឆ្នាំ៩១ពូមកដល់ម៉ាឡៃនេះមានព្រៃទេ?

ចាន់ថូ ៖ មានព្រៃទាំងអស់ មើលថ្ងៃមិនឃើញទេ ហើយពេលហ្នឹងក៏នៅមានគ្រុនច្រើនដែរ ។

វណ្ណៈ    ចឹងកាលហ្នឹងពូមានសង្កេតឃើញដើមឈើធំៗ ទេនិងមានសត្វព្រៃធំៗ ទេ?

ចាន់ថូ ៖ មានដើមឈើធំៗ មានសត្វព្រៃជាច្រើនហើយរាល់ថ្ងៃនេះសុទ្ធតែដើមឈើថ្មីៗ ទេ ។

វណ្ណៈ    បាទ ។

ចាន់ថូ ៖ ឯដើមចាស់អស់ហើយមិនមានទេ ។

វណ្ណៈ    ចឹងបើតាមពូដឹងព្រៃឈើចាប់អស់នៅឆ្នាំណាដែរ?

ចាន់ថូ ៖ តាមខ្ញុំគិតមើលចាប់ពី៩១ ឈើនៅមិនទាន់មានពីណារកទេ ប្រហែលជាឆ្នាំ៩៣-៩៤និង៩៥ តាមការសន្និដ្ឋានប្រហែលជាខ្ទង់ប៉ុណ្ណឹង ។

វណ្ណៈ    ចឹងកាលហ្នឹងព្រៃអស់ហើយចាប់ផ្ដើមកើតមានភូមិ?

ចាន់ថូ ៖ បាទ! កើតភូមិ ។

វណ្ណៈ    កាលហ្នឹងមានភូមិច្រើនទេ?

ចាន់ថូ ៖ នៅភូមិម៉ាឡៃនេះភូមិមានតែប៉ុណ្ណឹងដដែលហ្នឹង តែមានប្រជាជនតិច ។

វណ្ណៈ    ចឹងមានតិចមិនច្រើនដូចឥឡូវទេ?

ចាន់ថូ ៖ បាទ ។

វណ្ណៈ    ចឹងនៅតំបន់ម៉ាឡៃហ្នឹងតាមខ្ញុំដឹងដូចជាអគ្គការថ្នាក់លើមានការប្រមូលទ្រព្យសម្បត្តិឯកជនដាក់រួមតើមានរឿងហ្នឹងកើតឡើងនៅឆ្នាំ៩៣-៩៤មែនទេ?

ចាន់ថូ ៖ តាមខ្ញុំដឹងប្រហែលជាឆ្នាំជិតផ្ដាច់ខ្លួនប្រហែលជាកន្លះឆ្នាំទេ ។

វណ្ណៈ    ចឹងមានតែនៅក្នុងឆ្នាំ៩៦ដែរ?

ចាន់ថូ ៖ ឆ្នាំ៩៦ គិតទៅមុនប្រហែលជាកន្លះឆ្នាំ ។

វណ្ណៈ    ចឹងតា សុន សេនមិនទាន់ស្លាប់ទេ ។

ចាន់ថូ ៖ នៅទាំងអស់ សុន សេនហ្នឹងខ្ញុំដូចជាមិនច្បាស់ដែរ ប្រហែលជាផ្ដាច់ខ្លួនហើយគាត់ទៅដឹងតាមមើលបែបចឹងហើយ ព្រោះអីសុន សេនគាត់នៅកាន់ខាង៣២នោះណាស់ ។

វណ្ណៈ    ខាង៣២ខាងណា?

ចាន់ថូ ៖ ខាង៣២នៅសំពៅលូនរាល់ថ្ងៃហ្នឹង ដែលគេហៅថាតំបន់៣២នោះ គាត់នៅខាងជើងភ្នំ៣២ តែម្ដងកន្លែងគាត់នោះ និយាយរួមអ្នកនៅស្រុកម៉ាឡៃហ្នឹងទាំងមេទាំងទាហាន ប៉ូលីសទាំងអស់សុន សេនអត់មានទុកចិត្តទេ បញ្ជូនទាំងទាហានប៉ូលីសអ្នកទទួលខុសត្រូវមកគ្រប់គ្រងនៅទីនេះទាំងអស់ ។

វណ្ណៈ    បាទ ។

ចាន់ថូ ៖ មូលហេតុដែលផ្ដាច់ខ្លួនគឺចឹង ។

វណ្ណៈ   បាទ ។

ចាន់ថូ ៖ ទី១ប្រមូលរទេះគោ អាត្រាក់ឡានគោយន្តដាក់មួយដុំ ទី២បញ្ជូនកំលាំងទាំងអស់មកគ្រប់គ្រងនៅទីនេះ ។

វណ្ណៈ   ចឹងសុន សេន មានគំនិតចឹង?

ចាន់ថូ ៖ បាទ!សុន សេនមានគំនិតចឹងជាមួយតា ម៉ុកពីរហ្នឹង និយាយទាំងប្រធានកងពលទាំងអស់មានកំលាំងខាងសុន សេនមកគ្រប់គ្រង ។

វណ្ណៈ   ចឹងកាលហ្នឹងមានប្រមូលបានដែរតើ?

ចាន់ថូ ៖ មានប្រមូលបាន ។

វណ្ណៈ   តែក្រោយមកមានការប្រឆាំងគ្នាតើ?

ចាន់ថូ ៖ បាទ!មានប្រឆាំងហ្នឹងតា ម៉ុកគាត់មកដោះស្រាយនៅកន្លែងសារគាំងហ្នឹងឯង តែខ្ញុំមិនបានចូលរួមហ្នឹងគេទេ ។

វណ្ណៈ   បាទ ។

ចាន់ថូ ៖ តែខ្ញុំដឹងថាប្រជាជនពេលហ្នឹងមានការប្រឆាំងខ្លាំងណាស់ ។

វណ្ណៈ   ចឹងកាលហ្នឹងនៅ១០២ហ្នឹងគាណាជាអ្នកគ្រប់គ្រង?

ចាន់ថូ ៖ ១០២ហ្នឹងលោកអ៊ឹអៀង សារី តែអ៊ឹអៀង សារីមិនដឹងជាគាត់ទៅនៅណាបាត់ហើយទេ ។

វណ្ណៈ   គាត់សព្វថ្ងៃត្រូវបានតុលាការឃុំខ្លួនគាត់ជាបណ្តោះអាសន្ន?

ចាន់ថូ ៖ ចឹងណាស់ ប៉ុន្តែពេលគេចុះមកនេះអ៊ឹអៀង សារីក្រុមទាំងអស់នោះបដិសេធគាត់ចេញក្រៅអង្គភាពបាត់ហើយ ។

វណ្ណៈ   បាទ ។

ចាន់ថូ ៖ កាលសម័យហ្នឹង តែពូមុនហ្នឹងគាត់ជាអ្នកគ្រប់គ្រងលើតំបន់នេះទាំងអស់ ។

វណ្ណៈ   បាទ ។

ចាន់ថូ ៖ តែដល់ក្រោយមកមុនហ្នឹងពួកហ្នឹងមកដោះស្រាយហ្នឹងមិនដឹងជាគាត់បាត់ទៅណា ទើបក្រោយមកវិញ បានយើងដឹងថា ក្រោយពីប្រកាសផ្តាច់ខ្លួនចូលជាមួយរដ្ឋាភិបាលទើបអញ្ជើញគាត់មកឲ្យធ្វើជាប្រធានវិញ បានខ្ញុំដឹងថាអ្នកដឹកនាំទាំងអស់គ្នាបដិសេធគាត់ចោលបាត់ហើយ ។

វណ្ណៈ   ចឹងនៅម៉ាឡៃនេះ ប៉ុល ពតមានមកទេ?

ចាន់ថូ ៖ មានធ្លាប់មកដែលតែខ្ញុំមិនដែលឃើញ ។

វណ្ណៈ   ចឹងកាលហ្នឹងស៊ុន សេនគាត់មានអំណាចធំទេ?

ចាន់ថូ ៖ គាត់ជាអគ្គមេបញ្ជាការកងទ័ព ។

វណ្ណៈ  ចឹងក្រែងនៅតំបន់ហ្នឹងមានលោកអ៊ឹម អៀង សារីហើយហេតុអីបានជាគាត់ជ្រៀតមកទៀត?

ចាន់ថូ : និយាយមិនជ្រៀតយ៉ាងម៉េចបើអ៊ឹម អៀង សារីគេទាត់ចោលបាត់ហើយហ្នឹង ដល់នៅពេលផ្តាច់ខ្លួនគេអញ្ជើញគាត់មកធ្វើជាមេដឹកនាំសម្រាប់ផ្តាច់ខ្លួននេះ បាទខ្ញុំដឹងថាគេទាត់គាត់ចោលចឹងបានជាបាត់មុនគាត់រហូត ។

វណ្ណៈ  បាទ ។

ចាន់ថូ : ព្រោះយើងមិនអាចចូលជ្រៅបានទេ ចំពោះបញ្ហាយើងតូចតាចហើយការងាររបស់ខ្ញុំជាការងារសាលារៀនខ្ញុំមិនបានគិតពីរឿងនេះទេ ។

វណ្ណៈ  ចឹងពូនៅតែធ្វើគ្រូរហូត?

ចាន់ថូ : បាទ ។

វណ្ណៈ  ចឹងថ្វីត្បិតតែពូធ្វើជាគ្រូបង្រៀន តែពូមានបានដឹងរឿងរ៉ាវខ្លះៗ ដូចកាលហ្នឹងលោកតា ខៀវ សំផន គាត់ទៅរចរនៅភ្នំពេញហើយមានប្រជាជនធ្វើបាតកម្មហើយបានយកដុំថ្មចំក្បាលហូរឈាមអីហ្នឹង កាលហ្នឹងសុន សេនទៅដែលឬមួយយ៉ាងម៉េច?

ចាន់ថូ : តាមខ្ញុំដឹងសុន សេនក៏ទៅហ្នឹងដែរ ត្រង់ហ្នឹងហើយដែលខ្ញុំមិនសូវបានដឹង ចឹងហើយបានជាកើតឆ្ងល់ទៅទាំងអស់គ្នាហេតុអីបានជាមានគ្រោះថ្នាក់តែមួយ ហើយអ៊ំខៀវ សំផនយើងស្គាល់ប្រវត្តិគាត់ច្បាស់ហើយ ។

វណ្ណៈ  បាទ ។

ចាន់ថូ : ថាគាត់ហ្នឹងជាស្នេហាជាតិរបៀបណា តាំងពីគាត់ជាអ្នកដឹកនាំកាលពីសង្គមចាស់ ។

វណ្ណៈ  បាទ ។

ចាន់ថូ : គាត់ធ្វើតំណាងរាស្ត្រស្រុកស្អាងកាលហ្នឹង ។

វណ្ណៈ  បាទ ។

ចាន់ថូ : គេកើតឆ្ងល់ចឹងបានថា យើងមិនមែនជាអ្នកនយោបាយ តែយើងគ្រាន់តែឆ្ងល់ថាហេតុអីទៅទាំងអស់គ្នារងគ្រោះតែគាត់មួយ ។

វណ្ណៈ  ចឹងពូមានចាំឆ្នាំដែលលោកតា ខៀវ សំផនទៅ?

ចាន់ថូ : ខ្ញុំមិនបានចាំទេ កាលសម័យហ្នឹងដូចជាជំនាន់អ៊ុន តាក់ ។

វណ្ណៈ  បាទ!សម័យអ៊ុន តាក់ ។

ចាន់ថូ : អ៊ុនតាក់មុន៩៣ ព្រោះ៩៣យើងបោះឆ្នោតមិនចឹង ។

វណ្ណៈ  បាទ ។

ចាន់ថូ ៖ កាលហ្នឹងមានអ្នកទៅជាមួយនៅនេះដែរ រាល់ថ្ងៃហ្នឹង ខ្ញុំបានដឹងតាមរយៈទៅធ្វើការជាមួយតែឥឡូវគេនៅយើងនេះដែរ ។

វណ្ណៈ៖ ចឹងនៅពេលដែលលោកអ៊ីខៀវ សំផនមកវិញគាត់មានប្រជុំប្រាប់ប្រជាជនថា យើងទៅចរចាមិនបានសម្រេចទេយើងត្រូវធ្វើយ៉ាងម៉េច?

ចាន់ថូ ៖ គាត់មិនដែលបានមកទីនេះផង យើងគ្រាន់តែឮបាប់សភាពការណ៍ថាមេយើងទៅហ្នឹងទទួលមានបាតុកម្មវៃចឹងណាស់ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ តែអ្នកទាំងអស់គ្នាគ្រាន់តែសន្និដ្ឋានថា ហេតុអីសុន សេនជាអគ្គមេបញ្ជាការកងទ័ពហើយមនុស្សគាត់ប្រវត្តិយ៉ាងម៉េចយើងមិនដឹងទេ គេមិនទៅវៃសុន សេន ទៅវៃខៀវ សំផនដែលជាអ្នកនយោបាយល្អទៅវិញ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ នរណាក៏គេទទួលស្គាល់ថាខៀវ សំផន នយោបាយគាត់ល្អដែល យើងនិយាយមិនកើតទេព្រោះយើងអ្នកតូច ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ទោះបីខ្ញុំយល់ដឹងប៉ុណ្ណឹងហើយក៏ខ្ញុំមិនអាចនិយាយទៅបាន ហើយមិនអាចវិភាគទៅលើបញ្ហាអ៊ីបានទេ ព្រោះខ្ញុំជៀសណាស់បញ្ហានយោបាយនិយាយឲ្យត្រង់ ចឹងបានមកដល់មិញហ្នឹងខ្ញុំថាខ្ញុំមិនចង់និយាយជាមួយអ្នកណានិយាយពីរឿងអីទេ ខ្ញុំដោះខ្លួនខ្ញុំបានប៉ុណ្ណឹងហើយខ្ញុំផ្ដាំកូនចៅ ។

វណ្ណៈ៖ បាទ! ។

ចាន់ថូ ៖ ខ្ញុំមិនចង់ឲ្យជួបប្រទះទេ ។

វណ្ណៈ៖ ចឹងពូមិនចង់ឲ្យមានសង្គ្រាមទៀតទេ?

ចាន់ថូ ៖ បាទ!ព្រោះអីគោលបំណងខ្ញុំមិនចង់រៀនត្រឹមប៉ុណ្ណឹងទេ ជាអកុសលឲ្យចឹងខ្ញុំរៀនបានត្រឹមប្រេឌីបួមចឹងទេ តែប្រេឌីបួមពេលនោះ បាក់ឌុបឬបរិញ្ញាប័ត្រក៏ខ្ញុំមិនខ្លាចដែរ ។

វណ្ណៈ៖ ចឹងខ្ញុំចង់ពូនិយាយសង្ខេបថាពីឆ្នាំ៧៩មកតាំងពីសឡូត ចក្រី រហូតដល់ម៉ាឡៃនេះ កាលពីមុនសុទ្ធតែព្រៃឥឡូវក្លាយជាចំការដំឡូងអីចឹង ចឹងពូមើលឃើញភាពខុសគ្នាហ្នឹងយ៉ាងម៉េចដែរ?

ចាន់ថូ ៖ ខ្ញុំយល់ថាក្រោយពីគោលនយោបាយឈ្នះៗរបស់សម្ដេច ខ្ញុំឃើញថានយោបាយនេះល្អ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ សម្តេចគាត់មានយុទ្ធសាស្ត្រមួយត្រង់ថា ពេលប្រមូលពួកខ្មែរក្រហមឲ្យចូលទៅក្នុងជាមួយរដ្ឋាភិបាលដោយគាត់ប្រកាសថានយោបាយឈ្នះគឺគ្មាននរណាចាញ់ គ្មាននរណាឈ្នះគឺឈ្នះទាំងអស់គ្នា គឺខាងខ្មែរក្រហមនៅយ៉ាងម៉េចទុកនៅដដែរ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ចឹងហើយបានជាកំលាំងជាតិទាំងអស់គេទទួលស្គាល់គាត់ ចឹងខ្ញុំគិតថាសម្តេចនាយកគាត់មាននយោបាយនេះបានផ្សះផ្សារជាតិបាន ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ហើយយើងនៅមើលសកលលោកមានប្រទេសខ្លះនៅតែមានសង្គ្រាមនៅឡើយ ហើយប្រទេសខ្មែរយើងប៉ុន្មានសតវត្សមកហើយដែលគ្មានពីណាបញ្ចប់បាន ចឹងបានថានយោបាយរបស់សម្តេចបានល្អ ហើយយើងមើលឃើញសណ្ឋានភាពទាំងអស់ពីមុនសុទ្ធតែព្រៃខ្លាព្រៃដំរីមានជំងឺគ្រុនចាញ់រហូតដល់រាល់ថ្ងៃហ្នឹងមានផ្ទះសំបែង មានសុវត្ថភាពក្នុងការដាំដុះមានផលិតផលមានហូបចុះមានសំលៀកបំពាក់គ្រប់គ្រាន់មានហូបចុកគ្រប់គ្រាន់ បានបណ្តុះបណ្តាលឲ្យកូនរៀនសូត្របានប៉ុណ្ណឹងខ្ញុំអរហើយ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ អរត្រង់ថា ដូចជាខ្ញុំមានមតិពីរខាងដើមចឹង គំនិតតាំងពីដើមមកមិនចង់ឲ្យប្រទេសមានសង្គ្រាមបាក់បែកគ្រួសារបងប្អូនប្រពន្ធកូនអីអត់ទេ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ មានគំនិតតែមួយចង់ឲ្យគ្រួសារបងប្អូនប្រពន្ធកូនអីទេ ធ្វើម៉េចចង់ឲ្យប្រទេសជាតិមានការរីកចំរើនដូចជាប្រទេសជិតខាងចឹង ។

វណ្ណៈ៖ ចឹងខ្ញុំចង់សួរបន្តទាក់ទងនិងបងប្អូនយើងប្រកបមុខរបរទៅនៅស្រុកម៉ាឡៃនេះ ចឹងអ្នកស្រុកម៉ាឡៃនេះក្រៅពីប្រកបរបរធ្វើស្រែចំការហើយ តើមានទៅរកស៊ីឈ្នួលនៅស្រុកថៃទេ?

ចាន់ថូ ៖ អ្នកស្រុកម៉ាឡៃនេះសឹងថាមិនមានទៅស៊ីឈ្នួលនៅស្រុកថៃទេ បើមានក៏មានតិចដែរ តាមខ្ញុំដឹង អ្នកដែលចេញទៅស្រុកថៃមានអ្នកមកពីក្នុងប្រទេស អ្នកនៅក្នុងនេះមិនមានទេបើមានមានភាគតិច ភាគតិចហ្នឹងមិនមែនជាអ្នកស្រុកម៉ាឡៃទៀត អ្នកដែលមានតូចៗបេះហ្នឹងអាហ្នឹងគេមកស្នាក់នៅទេ តែចំពោះស្រុកម៉ាឡៃគេធ្វើតែរបស់គេមិនអស់ផង ភាគច្រើនអ្នកមកពីក្នុងប្រទេស ។

វណ្ណៈ៖ ចឹងនៅស្រុកម៉ាឡៃហ្នឹងការដាំដុះមានអីខ្លះ?

ចាន់ថូ ៖ មានពោត ដំឡូង សណ្តែកបាយ សណ្តែកសៀង មានល្ង ។

វណ្ណៈ៖ ចឹងដំណាំនៅស្រុកនេះមានសឹកតែគ្រប់ប្រភេទដែរ?

ចាន់ថូ ៖ បាទ ។

វណ្ណៈ៖ តែប្រជាជនទំរាំតែមានដីចំការហ្នឹងមានការគ្រោះថ្នាក់ដោយសារមីនច្រើន?

ចាន់ថូ ៖ គ្រោះថ្នាក់ដោយសារមីនគួរសមដែរ ។

វណ្ណៈ៖ ចឹងខ្ញុំចង់សួរពូថា មានភូមិដូងហេតុអីបានជាគេហៅថាភូមិដូង?

ចាន់ថូ ៖ ដូចជាពិបាកថា តាមពិតកាលហ្នឹងមានដើមដូងដាក់ភូមិដូងចឹងទៅ ។

វណ្ណៈ៖ ចឹង?

ចាន់ថូ ៖ កាលឆ្នាំ៨០ហ្នឹងយើងមិនទាន់ដាក់ថាភូមិដូងទេ ទាំងអស់នេះគេហៅថាជាតំបន់១០២មិនទាន់មានភូមិណាទេ ដល់ដាំដើមដូងដុះចឹងគេហៅភូមិដូងតាមខ្ញុំយល់ទេ ។

វណ្ណៈ៖ ចឹងចាប់មានភូមិឃុំពិតប្រាកដហ្នឹងនៅពេលណា?

ចាន់ថូ ៖ ភូមិហ្នឹងគេហៅភូមិដូងតាំងពីឆ្នាំ៨០-៨១ចឹងមក ។

វណ្ណៈ៖ ចឹងនៅពេលដែលមានភូមិឃុំស្រុកអីហ្នឹងចាប់ពីពេលណាមក?

ចាន់ថូ ៖ តាមការពិតទៅនៅពេលដែលផ្តាច់ខ្លួន បានមានបង្កើតភូមិស្អីៗភូមិស្អីៗចឹងទៅ ។

វណ្ណៈ៖ ចឹងភូមិពូគេហៅថាភូមិវាលហាត់ចឹង?

ចាន់ថូ ៖ ភូមិវាលហាត់នេះ តាមខ្ញុំដឹងវាលនេះសម្រាប់ហាត់ទាហាន មានទាំងដីរក៏មកហាត់នៅហ្នឹង ហើយកន្លែងនេះជាកន្លែងហាត់ទ័ពគេ ដីកន្លែងសាលារៀនហ្នឹងជាកន្លែងហាត់ទ័ពព្រោះកន្លែងហ្នឹងជាវាលខ្សាច់ ។

វណ្ណៈ៖ ចឹងបានដាក់ថាភូមិវាលហាត់?

ចាន់ថូ ៖ បាទ!ភូមិវាលហាត់ ។

វណ្ណៈ៖ ចឹងខ្ញុំចង់សួរពូរឿងទាក់ទងហ្នឹងតុលាការកាត់ទោស ទោះបីពូធ្លាប់ឆ្លងកាត់តែពូមិនបានជួបការលំបាកក៏ដោយ តែពូបានជួបសង្គ្រាមមិនចង់ឲ្យមានសង្គ្រាម តែនៅស្រុកខ្មែរយើងមានមនុស្សជាងមួយលាននាក់ចឹង ហើយស្រុកខ្មែរយើងបានចូលរួមជាមួយអង្គការសហប្រជាជាតិដល់ក្រោយមកអង្គការសហប្រជាជាតិចង់ឲ្យយើងមានតុលាការមួយសម្រាប់កាត់ទោសដែលបានប្រព្រឹត្តខុសក្រិដ្ឋកម្មធ្ងន់ធ្ងរមួយមកលើប្រជាជនគេសំអាងទៅលើសិទ្ធមនុស្សហើយតុលាការហ្នឹងក៏សហការជាមួយតុលាការកម្ពុជាយើងដែរ ចឹងតាមគំនិតពូការបង្កើតតុលាការហ្នឹងជាការត្រឹមត្រូវឬមិនត្រឹមត្រូវទេ?

ចាន់ថូ ៖ រឿងបញ្ហាហ្នឹងខ្ញុំមិនមានអីជំទាស់ទេ ព្រោះអ៊ីៗសំខាន់ថាប្រទេសយើងមានច្បាប់ ចឹងច្បាប់ធ្វើអ៊ីៗត្រឹមត្រូវជាច្បាប់របស់ប្រទេសមួយ សម្រាប់ខ្ញុំម្នាក់ឬអ្នកណាម្នាក់ទៀតថាមិនត្រូវធ្វើទេ

មិនត្រូវវិលត្រឡប់ទៅរឿងចឹងវិញទេ យើងមិនត្រូវកកូរកកាយរឿងបញ្ហាហ្នឹងទេ ធ្វើយ៉ាងម៉េចឲ្យតែកម្ពុជាមានសន្តិភាព ។

វណ្ណៈ: បាទ ។

ចាន់ជូ : ខ្ញុំនិយាយតែប៉ុណ្ណឹង ។

វណ្ណៈ: ចឹងពូមានគំនិតផ្សះផ្សារចង់ឲ្យមានខ្មែរតែមួយកុំឲ្យមានការបែងចែកពួចង់មានចឹងទេ?

ចាន់ជូ : ខ្ញុំចង់និយាយចេះ របបដែលគេហៅថាខ្មែរក្រហមរាល់ថ្ងៃនេះ មិនមែនពួកខ្ញុំជាអ្នកឲ្យពណ៌ខ្លួនឯងទេ ចឹងរាល់ថ្ងៃនៅតែមានគេហៅថាជាខ្មែរក្រហមរហូតហ្នឹង ខ្ញុំពុពាក្យប៉ុណ្ណឹងខ្ញុំថា ល្មមឈប់សឈប់ក្រហមទៀតទៅ ។

វណ្ណៈ: បាទ ។

ចាន់ជូ : ដូច្នេះបើពួកអញមិនចូលក៏ពួកឯងមិនបានសុខដែរ ដូចនេះអញមិនបានហៅពួកឯងថាជាខ្មែរអីទេ ។

វណ្ណៈ: បាទ ។

ចាន់ជូ : ឯងកុំដាក់ពណ៌ឲ្យពួកអញខ្លាំងពេក តាមពិតទៅខ្ញុំមិនខ្វាចទេ ។

វណ្ណៈ: ត្រូវ ។

ចាន់ជូ : ព្រោះខ្ញុំមិនមានគំនិតដូចអាពួកហ្នឹងថាទេ ច្រើនតែអាពួកហ្នឹងនិយាយថាខ្មែរក្រហមៗ ហើយខ្មែរក្រហមពួកណាជាអ្នកដាក់មានតែពួកហ្នឹងហើយជាអ្នកដាក់ឲ្យនោះ មិនដែលពួកខ្ញុំហៅខ្លួនឯងជាខ្មែរក្រហមទេ ។

វណ្ណៈ: ចឹងថ្ងៃក្រោយពូមិនចង់ឲ្យមានការហៅចឹងទេ?

ចាន់ជូ : មិនចង់ឲ្យមានខ្មែរពីរបីទេ មិនចង់ឲ្យមានខ្មែរក្រហម ខ្មែរស ខ្មែរខៀវ ខ្មែរច្រើនហ្នឹងហើយដែលមិនត្រូវគ្នានោះ ឲ្យតែមានបែកចែកពណ៌សម្បុរគឺបញ្ហាឈ្លោះគ្នាហើយ ។

វណ្ណៈ: បាទ ។

ចាន់ជូ : ចឹងបានជាខ្ញុំសរសេរសម្តេចនាយកនិយាយឲ្យត្រង់មួយម៉ាត់ ។

វណ្ណៈ: ចឹងពូមានគំនិតផ្សះផ្សារមិនចង់ឲ្យមានការបែកចែក?

ចាន់ជូ : បាទ ។

វណ្ណៈ: ចឹងពូមិនចង់ឲ្យមានសង្គ្រាម?

ចាន់ជូ : បាទ!មិនចង់ឲ្យមានខ្មែរក្រហមខ្មែរខៀវតទៅទៀត គឺមានខ្មែរតែមួយរួមគ្នាក៏សាងប្រទេសតាមនយោបាយរបស់សម្តេចល្អណាស់ ។

វណ្ណៈ: ចឹងខ្ញុំដូចជាអត់មានអីសួរបន្តទៀតហើយ ចឹងខ្ញុំសូមអរគុណពូច្រើនហើយ ។

ចាន់ថូ ៖ បាទ!អរគុណ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ខ្ញុំនិយាយហ្នឹងគឺនិយាយត្រង់ដូចបំណងខ្ញុំពីដើមមកចឹងណាស់ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ហើយបំណងខ្ញុំរាល់ថ្ងៃខ្ញុំធ្វើជិតបានសម្រេចរបស់ខ្ញុំហើយ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ខ្ញុំរៀនបានប៉ុណ្ណឹងចាត់ទុកដូចជាអកុសលរបស់ខ្ញុំតែកូនខ្ញុំត្រូវឲ្យរៀនទាល់តែចប់ទាំងអស់ ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ ចឹងអស់ប្អូននាក់ហើយនៅសល់តែមួយទៀត អាមួយទៀតក៏ឲ្យឯងរៀនទាល់តែចប់ទៀត ។

វណ្ណៈ៖ បាទ ។

ចាន់ថូ ៖ រឿងក្រប្អមានខ្ញុំមិនបានគិតទេ ។

វណ្ណៈ៖ បាទ!ចឹងខ្ញុំអរគុណពូច្រើនហើយ ។

ចាន់ថូ ៖ បាទ ។

**«ចប់»**